ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "ង"

លេខ 3224 ត.ព្រ

## ដីកាលើកលែងចោទប្រកាន់

យើង [redacted] វណ្ណី ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក [redacted] ស៊ុនតិច ជាក្រឡាបញ្ជី ។

បានឃើញមាត្រា ២៤៧ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៧៩២ ចុះថ្ងៃទី ១២-០៣-២០១១

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៦៩៨ យ,អ,ច ចុះថ្ងៃទី ០៧-០៤-២០១១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញសំណុំរឿងស៊ើបសួរលេខ ៦៤៧ ចុះថ្ងៃទី ០៧-០៤-២០១១

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ១៣២២ អ,យ,ច ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

**ក្រោយពីបានស៊ើបសួរ និងពិនិត្យសំណុំរឿងចប់សព្វគ្រប់ឃើញថា:** កាលពីក្នុងឆ្នាំ ២០១០ ឈ្មោះ [redacted] **សេងហ៊ួយ** ភេទស្រី អាយុ៤២ឆ្នាំ និងកូនស្រីឈ្មោះ [redacted] **កុសិតា** អាយុ១០ឆ្នាំ បានធ្វើដំណើរទៅលេងនៅប្រទេសវៀតណាមជាមួយឈ្មោះ [redacted] **អង្គារ៉ា** ភេទប្រុស អាយុ៤១ឆ្នាំ។ នៅពេលទៅដល់ប្រទេសវៀតណាមអ្នកទាំងបីបានស្នាក់នៅសណ្ឋាគារមួយបន្ទប់រួមគ្នាជាមួយអ្នករួមដំណើរផ្សេងទៀត ។ លុះពេលយប់កំពុងតែសំរាកឈ្មោះ [redacted] **អង្គារ៉ា** បានលូកស្ទាបអង្អែលប្រដាប់ភេទជនរងគ្រោះឈ្មោះ [redacted] **កុសិតា** ដែលបានគេងគ្រែជាមួយគ្នា បន្ទាប់មកឈ្មោះ **ឆាយ សេងហ៊ួយ** ដែលជាម្តាយបានអោបថើបគ្នារួមភេទជាមួយឈ្មោះ [redacted] **អង្គារ៉ា** នៅចំពោះមុខជនរងគ្រោះ ។ នៅក្នុងឆ្នាំ ២០១០ ដដែលឈ្មោះ [redacted] **អង្គារ៉ា** បានធ្វើដំណើរទៅលេងខេត្តមណ្ឌលគិរីជាមួយឈ្មោះ [redacted] **សេងហ៊ួយ** និងកូនស្រីឈ្មោះ [redacted] **កុសិតា** ទៀត ។ នៅខេត្តមណ្ឌលគិរីទាំងបីបានដេកបន្ទប់រួមគ្នាទៀតខណៈនោះឈ្មោះ [redacted] **សេងហ៊ួយ** បានអោបថើបគ្នាដេកជាមួយឈ្មោះ [redacted] **អង្គារ៉ា** ចំពោះមុខកូន លុះព្រឹកឡើងពេលនាំគ្នាទៅលេងទឹកជ្រោះឈ្មោះ [redacted] **អង្គារ៉ា** បានធ្វើសកម្មភាពដោយយកម្រាមដៃចាក់ក្នុងប្រដាប់ភេទជនរងគ្រោះម្តងទៀត។

-បានឃើញចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] **អង្គារ៉ា** ហៅ **ពៅ** ភេទប្រុស អាយុ ៤១ឆ្នាំ បានឆ្លើយថា ខ្លួន និងឈ្មោះ [redacted] **សេងហ៊ួយ** ជាមិត្តភ័ក្តិនឹងគ្នាតាំងពីនៅតូចៗមកម្ល៉េះ ទើបតែបានជួបគ្នានៅក្នុងឆ្នាំ២០០៨ នេះទេហើយក៏បានទំនាក់ទំនងគ្នារហូតមក ។ នៅក្នុងឆ្នាំ២០១០ ខ្លួននិងឈ្មោះ [redacted] **សេងហ៊ួយ** ព្រមទាំងបងប្អូននិងកូនរបស់ឈ្មោះ [redacted] **សេងហ៊ួយ** មានគ្នាទាំងអស់៦នាក់បានទៅមើលជម្ងឺនៅប្រទេសវៀតណាម ។ នៅពេលទៅដល់យើងទាំងអស់គ្នាបានជួលបន្ទប់តែមួយស្នាក់រួមគ្នាដោយបន្ទប់នោះមានគ្រែ២ ដោយខ្លួនគេងជាមួយឈ្មោះ [redacted] **សេងហុក** ហើយគ្រែមួយទៀតឈ្មោះ [redacted] **សេងហ៊ួយ** គេងជាមួយកូនគាត់ទាំងបីនាក់ ខ្លួនមិនបាន ...

ប្រព្រឹត្តដូចការចោទប្រកាន់ទេ។ លុះក្រោយមកទៀតនៅឆ្នាំ២០១០ ដដែលបងស្រីខ្លួនឈ្មោះ [redacted] **ណារី** មកពីបារាំងគាត់ចង់ទិញដីនៅខេត្តមណ្ឌលគិរី ក្នុងពេលនោះឈ្មោះ [redacted] **សេងហ៊ួយ** បានរួមដំណើរជាមួយដែរដោយមានប្អូនគាត់ឈ្មោះ [redacted] **សេងហុក** ប្រពន្ធវា និងកូនក៏ទៅដែរ។ នៅពេលទៅដល់យើងបានជួលបន្ទប់ស្នាក់នៅចំនួន២ ដោយខ្លួនដេកជាមួយឈ្មោះ [redacted] **សេងហុក** ហើយឈ្មោះ [redacted] **សេងហ៊ួយ** ដេកជាមួយប្រពន្ធរបស់ឈ្មោះ [redacted] **សេងហុក** និងកូនស្រីគាត់ឈ្មោះ [redacted] **កុសិតា** ។ លុះព្រឹកឡើងបាននាំគ្នាទៅលេងទឹកជ្រោះប៊ូស្រា ខ្លួនមិនបានចុះលេងទឹកជាមួយឈ្មោះ [redacted] **កុសិតា** តែពីរនាក់ទេ ។ ខ្លួនសូមបញ្ជាក់ថា ខ្លួនមិនបានលេងប្រដាប់ភេទរបស់កុមារីឈ្មោះ [redacted] **កុសិតា** ទេ ។

-បានឃើញចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] **សេងហ៊ួយ** ភេទស្រី អាយុ៤២ឆ្នាំ បានឆ្លើយថា នៅឆ្នាំ ២០១០ ខ្លួនពិតជាបានទៅមើលជម្ងឺនៅប្រទេសវៀតណាមជាមួយឈ្មោះ [redacted] **អង្គារ៉ា** ប្រាកដមែន ដោយខ្លួនទៅមានគ្នា៦នាក់មានឈ្មោះ **ឆាយ សេងហុក** ឈ្មោះ [redacted] **អង្គារ៉ា** និងកូនរបស់ខ្លួនបីនាក់ឈ្មោះ [redacted] **នរតី** ឈ្មោះ [redacted] **កុសិតា** និងឈ្មោះ [redacted] **សុបញ្ញាវ័ន្ត** ។ ពេលទៅដល់ប្រទេសវៀតពួកខ្លួនបានជួលបន្ទប់គេងតែមួយព្រោះសណ្ឋាគារនោះអស់បន្ទប់ ហើយក៏ស្នាក់នៅបន្ទប់តែមួយដោយបន្ទប់នោះមានគ្រែបី គ្រែ២រុញចូលគ្នាដោយខ្លួនគេងជាមួយកូនទាំងបីនាក់ ហើយឈ្មោះ [redacted] **អង្គារ៉ា** គេងជាមួយឈ្មោះ [redacted] **សេងហុក** ។ ក្នុងយប់នោះខ្លួនមិនបានគេងជាមួយឈ្មោះ [redacted] **អង្គារ៉ា** ទេ ហើយឈ្មោះ [redacted] **អង្គារ៉ា** ក៏មិនបានអោបថើប ឬក៏ស្ទាបអង្អែលលើកូនស្រីខ្លួនដែរ ។ នៅក្នុងឆ្នាំ ២០១០ បងស្រីរបស់ឈ្មោះ [redacted] **អង្គារ៉ា** មកពីប្រទេសបារាំងគាត់ចង់ទៅមើលដី ដោយខ្លួនមិនធ្លាប់ស្គាល់ផងខ្លួនក៏បានទៅជាមួយគាត់មានគ្នា៤នាក់គឺមានខ្លួន កូនស្រីខ្លួនឈ្មោះ [redacted] **កុសិតា** ប្អូនប្រុសខ្លួនឈ្មោះ **ឆាយ សេងហុក** និងប្អូនថ្លៃខ្លួនប្រពន្ធរបស់ឈ្មោះ [redacted] **សេងហុក** ហើយឈ្មោ[redacted] **អង្គារ៉ា** បានទៅជាមួយបងស្រីគាត់២នាក់ទៀត ។ នៅពេលទៅដល់យើងបានជួលបន្ទប់ស្នាក់នៅចំនួន២ ដោយខ្លួនដេកគ្រែមួយគ្នាបីនាក់ គឺខ្លួន កូនស្រីខ្លួន និងប្អូនថ្លៃខ្លួន ឯគ្រែមួយទៀតឈ្មោះ [redacted] **អង្គារ៉ា** គេងជាមួយឈ្មោះ [redacted] **សេងហុក** ចំណែកបន្ទប់មួយទៀតបងស្រីរបស់ឈ្មោះ [redacted] **អង្គារ៉ា** គេងគ្នាគាត់២នាក់ ។ លុះព្រឹកឡើងបាននាំគ្នាទៅលេងទឹកជ្រោះប៊ូស្រា ដោយកូនស្រីខ្លួននៅជាមួយខ្លួន និងប្អូនថ្លៃខ្លួន ឯឈ្មោះ [redacted] **អង្គារ៉ា** គាត់បានឡើងទៅទីខ្ពស់មិននៅជិតពួកខ្លួនទេ។ ពេលត្រលប់មក ផ្ទះវិញកូនខ្លួនស្រីមិនបានប្រាប់ខ្លួនថាឈឺប្រដាប់ភេទនោះទេ ហើយនៅខេត្តមណ្ឌលគិរីខ្លួនមិនបានគេងជាមួយឈ្មោះ [redacted] **អង្គារ៉ា** ទេហើយឈ្មោះ [redacted] **អង្គារ៉ា** ក៏មិនបានស្ទាបអង្អែលកូនស្រីខ្លួនដែរ ។

accused

-បានឃើញចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] **កុសិតា** បានឆ្លើយថា ខ្លួនធ្លាប់ទៅប្រទេសវៀតណាមជាមួយម្ដាយខ្លួននិងឈ្មោះ [redacted] **អង្គារ៉ា** នៅក្នុងឆ្នាំ២០១០ ។ នៅពេលទៅដល់ប្រទេស



Scanned with CamScanner

វៀតណាមពួកខ្លួនបាននៅសណ្ឋាគារពេលនោះគេងបន្ទប់មួយ៤នាក់ គ្រែ២ហើយបានរុញគ្រែឱ្យជាប់គ្នាគ្រែ២គេងគ្នា៤នាក់ វេលាម៉ោងប្រហែលជា៨យប់ឈ្មោះ [redacted] **អង្គារ៉ា** បានគេងជិតម្តាយខ្លួន ពេលនោះខ្លួនឃើញក៏បានទៅគេងកណ្តាលរវាងម្តាយខ្លួន និងឈ្មោះ [redacted] **អង្គារ៉ា** ហើយឈ្មោះនេះបានស្ទាបអង្អែលពេញទាំងខ្លួនប្រាណរបស់ខ្លួនដោយទ្រាំមិនបានខ្លួនក៏រត់ចេញហើយអោយបងស្រីខ្លួនទៅគេងកន្លែងនោះវិញហើយឈ្មោះ [redacted] **អង្គារ៉ា** ក៏បានស្ទាបបងស្រីខ្លួនដូចខ្លួនដែរ ហើយបងស្រីខ្លួនរត់ចេញមកគេងជិតខ្លួនវិញ ។ លុះក្រោយមកម៉ោងប្រហែលជា១១យប់ ដោយរង្គើលពួកខ្លួនក៏ភ្ញាក់ពេលនោះខ្លួនឃើញម្តាយខ្លួន និងឈ្មោះ [redacted] **អង្គារ៉ា** អោបថើបគ្នាខ្លួនឃើញឈ្មោះ [redacted] **អង្គារ៉ា** នៅពីលើម្តាយខ្លួនរួចផ្លាស់គ្នាវិញដោយម្តាយខ្លួននៅពីលើវិញ ។ លុះព្រឹកឡើងម្តាយខ្លួន និងបងស្រីខ្លួនបានចេញទៅទិញក្តាមដោយទុកខ្លួនឱ្យនៅជាមួយឈ្មោះ [redacted] **អង្គារ៉ា** ពេលម្តាយខ្លួនទៅបាត់ឈ្មោះ [redacted] **អង្គារ៉ា** បានយកម្រាមដៃលូកចូលប្រដាប់ភេទខ្លួន ពេលនោះខ្លួនឈឺខ្លួនក៏យំដោយមិនមានចេញឈាមទេ ខ្លួនមិនបានរត់ចេញពីបន្ទប់ទេ ដោយឈ្មោះ [redacted] **អង្គារ៉ា** បានគំរាមខ្លួនថា កុំឱ្យប្រាប់អ្នកណាអោយសោះដោយគាត់លើកដៃជាសញ្ញាកាត់ក ។ ក្រោយមកខ្លួនបានទៅលេងនៅខេត្តមណ្ឌលគិរី ដោយមានគ្នា៧នាក់ ពេលនោះក៏បានជួលបន្ទប់២គឺ បន្ទប់១គេងគ្នា៣នាក់ ហើយមួយទៀតគេងគ្នា៤នាក់ ដោយបន្ទប់ខ្លួនគេងគ្នា៣នាក់គឺខ្លួន ម្តាយខ្លួន និងឈ្មោះ [redacted] **អង្គារ៉ា** ដំបូងឡើយម្តាយខ្លួនជាមួយខ្លួន លុះដល់ពាក់កណ្តាលអាធ្រាតខ្លួនឃើញម្តាយខ្លួនទៅគេងជាមួយឈ្មោះ [redacted] **អង្គារ៉ា** ហៅ **ពៅ** ខ្លួនក៏ហៅម្តាយខ្លួនអោយមកគេងជាមួយខ្លួនវិញ ។ លុះព្រឹកឡើងខ្លួនក៏ឃើញម្តាយខ្លួនគេងជាមួយឈ្មោះ **ពៅ** ទៀតខ្លួនក៏សួរម្តាយៗប្រាប់ថា ខ្លាចដេញទើបបានទៅគេងជាមួយឈ្មោះ **ពៅ** ព្រោះឈ្មោះ **ពៅ** មានបន្តោងព្រះ ។ បន្ទាប់មកពួកខ្លួនទាំងអស់គ្នាបានទៅលេងទឹកជ្រោះប៊ូស្រា ខ្លួនបានផ្លាស់សំលៀកបំពាក់ហើយមុនគេជាមួយឈ្មោះ **ពៅ** ហើយពេលនៅក្នុងទឹកឈ្មោះ **ពៅ** បានអោនថើបក្បាលពោះខ្លួនរួចក៏យកម្រាមដៃចាក់ចូលប្រដាប់ភេទខ្លួនៗឈឺក៏យំ រយះពេល២ទៅ៣នាទី ពេលនោះម្តាយខ្លួនទៅដល់ឈ្មោះ **ពៅ** ក៏ធ្វើជាជះទឹកលេងពេលនោះខ្លួនមិនបានប្រាប់ម្តាយខ្លួនភ្លាមទេ ។ លុះមកដល់ផ្ទះខ្លួនបានប្រាប់គាត់ថា ឈឺប្រដាប់ភេទ គាត់ថា ទៅនោមទៅ ខ្លួនថា នោមហើយ គាត់ក៏ មិនរវល់និងខ្លួនទេ។ នៅប្រទេសវៀតណាមគាត់ឃើញឮ **ពៅ** ស្ទាបខ្លួនដែរតែគាត់ធ្វើជាមើលទូរទស្សន៍ ។

-បានឃើញចម្លើយរបស់ឈ្មោះ [redacted] **ចន្ថា** បានឆ្លើយថា ប្រពន្ធរបស់ខ្លួនបានទំនាក់ទំនងជាមួយឈ្មោះ [redacted] **អង្គារ៉ា** លុះដល់ឆ្នាំ២០១០ ទើបកូនប្រាប់ខ្លួនថាប្រពន្ធខ្លួនមានទំនាក់ទំនង

ជាមួយឈ្មោះ [redacted] អង្គ៉ា នៅប្រទេសវៀតណាម ។ ក្នុងឆ្នាំ២០០៩ ខ្លួនបានរស់នៅបែកគ្នាចន្លោះពីខែ មីនា ទៅខែមិថុនា ឆ្នាំ២០១០ ប្រពន្ធខ្លួនបានទៅយកកូនចេញនៅមន្ទីរពេទ្យឯកជនដោយបានកុហកថាទៅបូមឈាមកកចេញពីក្នុងស្បូន កូនស្រីខ្លួនបានប្រាប់ខ្លួនថាឈ្មោះ [redacted] អង្គ៉ា បានយកម្រាមដៃលូកប្រដាប់ភេទកូនខ្លួនក្នុងអំឡុងពេលកូនខ្លួនទៅប្រទេសវៀតណាម និងនៅខេត្តមណ្ឌលគិរី ខ្លួនមិនបានឃើញផ្ទាល់ភ្នែកទេ ហើយខ្លួនក៏មិនបានបង្គាប់ឱ្យកូននិយាយដែរ ខ្លួនទាមទារជម្ងឺចិត្តពីឈ្មោះ [redacted] អង្គ៉ា និងប្រពន្ធខ្លួនចំនួន ១៥០,០០០ ដុល្លា (ដប់ប្រាំម៉ឺនដុល្លាអាមេរិក) ។

-បានឃើញចម្លើយរបស់សាក្សីឈ្មោះ [redacted] នរតី បានឆ្លើយបញ្ជាក់ថា ខ្លួនបានទៅប្រទេសវៀតណាមកាលពីឆ្នាំ២០១០ ដោយមានគ្នាចំនួន៦នាក់ដោយនៅសណ្ឋាគារគ្មានបន្ទប់ច្រើនក៏បានជួលបន្ទប់មួយស្នាក់គ្នា៦នាក់ ខ្លួនគេងជាមួយម្តាយនិងប្អូនខ្លួន២នាក់ទៀត ចំណែកឈ្មោះ [redacted] អង្គ៉ា គេងជាមួយឈ្មោះ [redacted] សេងហុក ។ ខ្លួនមិនបានឃើញម្តាយខ្លួនអោបថើបគ្នាជាមួយឈ្មោ[redacted] អង្គ៉ា នោះទេ ហើយឈ្មោះ [redacted] អង្គ៉ា មិនបានមកគេងជិតម៉ាក់ខ្លួនឬជិតខ្លួនដែរ ហើយក៏មិនបានឃើញឈ្មោះ [redacted] អង្គ៉ា ស្ទាប់អង្អែលប្អូនខ្លួន ឬក៏លេងប្រដាប់ភេទប្អូនខ្លួនដែរ ម្តាយខ្លួនមិនបានទុកប្អូនខ្លួនអោយនៅសណ្ឋាគារជាមួយឈ្មោះ [redacted] អង្គ៉ា តែពីរនាក់ដែរ ។ ឪពុកខ្លួនបានបង្គាប់ឱ្យខ្លួនឆ្លើយថា ម្តាយខ្លួនមានសាហាយជាមួយឈ្មោះ [redacted] អង្គ៉ា ហើយឈ្មោះ [redacted] អង្គ៉ា បានធ្វើសកម្មភាពផ្សេងៗមកលើខ្លួន ។

-បានឃើញចម្លើយរបស់សាក្សីឈ្មោះ [redacted] សេងហុក បានឆ្លើយថា កាលពីឆ្នាំ២០១០ ខ្លួនបានទៅប្រទេសវៀតណាមជាមួយបងស្រីខ្លួនឈ្មោះ [redacted] សេងហ៊ួយ និងឈ្មោះ [redacted] អង្គ៉ា និងក្មួយខ្លួន៣នាក់ទៀត។នៅពេលទៅដល់ពួកខ្លួនបានជួលបន្ទប់ស្នាក់រួមគ្នាដោយមានគ្រែ៣ ខ្លួនគេងជាមួយឈ្មោះ [redacted] អង្គ៉ា ចំណែកបងស្រីគេងជាមួយក្មួយខ្លួន៣នាក់ទៀត ។ ពេលចេញពីសណ្ឋាគារគឺទៅទាំងអស់គ្នាដោយមិនបានទុកក្មួយខ្លួនឈ្មោះ [redacted] កុសិតា ឱ្យនៅជាមួយឈ្មោះ [redacted] អង្គ៉ា នោះទេ ។ ក្រោយមកពួកខ្លួនបានទៅលេងនៅខេត្តមណ្ឌលគិរីទៀតដោយបានជួលបន្ទប់ស្នាក់នៅចំនួន២គឺបន្ទប់មួយបងស្រីរបស់ឈ្មោះ [redacted] អង្គ៉ា ស្នាក់នៅចំនួន២នាក់ ហើយបន្ទប់មួយទៀតមានបងស្រីខ្លួនគេងជាមួយកូនគាត់ ខ្លួន ប្រពន្ធខ្លួន និងឈ្មោះ [redacted] អង្គ៉ា ។ ដោយឈ្មោះ [redacted] អង្គ៉ា គេងគ្រែជាមួយខ្លួន ពេលទៅលេងទឹកជ្រោះគឺចុះលេងតែម្តងដោយមិនបានផ្លាស់សំលៀកបំពាក់ទេហើយពេលចុះទៅលេងទឹកគឺឈ្មោះ [redacted] អង្គ៉ា មិនបានចុះទៅមុនជាមួយក្មួយស្រីខ្លួនឈ្មោះ [redacted] កុសិតា នោះទេ ។



Scanned with CamScanner

-បានឃើញចម្លើយរបស់សាក្សីឈ្មោះ [redacted] វណ្ណៈ បានឆ្លើយថា កាលពីឆ្នាំ២០១០ ពួកខ្លួនបានទៅលេងនៅខេត្តមណ្ឌលគិរីដោយមានគ្នា៧នាក់ មានខ្លួន ប្តីខ្លួន បងថ្លៃខ្លួនឈ្មោះ [redacted] **សេងហ៊ួយ** ក្មួយខ្លួនឈ្មោះ [redacted] **កុសិតា** ឈ្មោះ [redacted] **អង្គារ៉ា** និងបងស្រីរបស់ឈ្មោះ [redacted] **អង្គារ៉ា** ចំនួន២នាក់ទៀត ។ ឈ្មោះ [redacted] **អង្គារ៉ា** មិនបានធ្វើសកម្មភាពអ្វីទៅលើក្មួយស្រីរបស់ខ្លួនឈ្មោះ [redacted] **កុសិតា** នោះទេ ។

## យល់ឃើញថា

-ជនត្រូវចោទឈ្មោះ [redacted] **សេងហ៊ួយ** ភេទស្រី អាយុ៤២ឆ្នាំ ជាតិខ្មែរ មុខរបររកស៊ីពាណិជ្ជករ កើតនៅទីរួមខេត្តកំពត ទីលំនៅបច្ចុប្បន្នផ្ទះលេខ ៤AE$_0$ ផ្លូវ១១២ សង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] “រ” ម្តាយឈ្មោះ [redacted]ស” ប្តីឈ្មោះ [redacted] មានកូន៦នាក់ ទោសពីមុនគ្មាន ជានីតិជន ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ ជិត និង **អំពើអាសប្រឆាំងនឹងអនីតិជនអាយុ ក្រោម១៥ឆ្នាំ** ប្រព្រឹត្តនៅប្រទេសវៀតណាម និងខេត្តមណ្ឌលគិរី កាលពីឆ្នាំ ២០១០ តាមបញ្ញត្តិមាត្រា ៧ នៃច្បាប់ស្តីពីឯកពន្ធភាព និងមាត្រា ៤៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

-ជនត្រូវចោទឈ្មោះ [redacted] **អង្គារ៉ា** ហៅ **ពៅ** ភេទប្រុស អាយុ៤១ឆ្នាំ ជាតិខ្មែរ សញ្ជាតិបារាំង មុខរបររកស៊ីធ្វើចំការនៅបារាំង កើតនៅសង្កាត់លេខ៥ រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្ន [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] “ស” ម្តាយឈ្មោះ [redacted] “ស” ប្រពន្ធឈ្មោះ [redacted] “រ” មានកូន៥នាក់ ទោសពីមុនគ្មាន ជានីតិជន ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ **អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ** ប្រព្រឹត្តនៅប្រទេសវៀតណាម និងខេត្តមណ្ឌលគិរី កាលពីឆ្នាំ ២០១០ តាមបញ្ញត្តិមាត្រា ៤៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

-តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] **កុសិតា** បានឆ្លើយថា ក្នុងពេលស្នាក់នៅសណ្ឋាគារនៅប្រទេសវៀតណាម ខ្លួនបានឃើញឈ្មោះ [redacted] **អង្គារ៉ា** នៅលើម្តាយខ្លួនហើយក្រោយមកបានឆ្លាសគ្នាដោយឈ្មោះ [redacted] **សេងហ៊ួយ** នៅពីលើឈ្មោះ [redacted] **អង្គារ៉ា** វិញ ក្នុងពេលដែលខ្លួនភ្ញាក់ពេលដែលរង្គើលគ្រែក្នុងពេលយប់ជ្រៅនោះ តុលាការពុំអាចជឿបានទេ ។

-ពុំមានភស្តុតាង រឺឯកសារណាដែរបញ្ជាក់ថាមានស្លាកស្នាមលើប្រដាប់ភេទជនរងគ្រោះឈ្មោះ [redacted] **កុសិតា** ដែរ ។

-តាមចម្លើយរបស់ឈ្មោះ [redacted] **អង្គារ៉ា** និងឈ្មោះ [redacted] **សេងហ៊ួយ** និងឈ្មោះ [redacted] **សេងហុក** ជាសាក្សីបានឆ្លើយស៊ីសង្វាក់គ្នាថា ក្នុងពេលនៅប្រទេសវៀតណាមក្នុងឆ្នាំ២០១០ ពួកខ្លួនស្នាក់នៅមានគ្នា៦នាក់ហើយស្នាក់នៅសណ្ឋាគារគឺពួកខ្លួនទាំងអស់គ្នាស្នាក់នៅក្នុងបន្ទប់តែមួយដោយមានគ្រែ២ គឺគ្រែមួយសំរាប់ឈ្មោះ [redacted] **សេងហ៊ួយ** គេងជាមួយកូន រីឯគ្រែមួយ ៕



Scanned with CamScanner

ទៀតគឺឈ្មោះ [redacted] សេងហ៊ួយ គេងជាមួយឈ្មោះ [redacted] អង្គារ៉ា ចម្លើយនេះអាចអោយតុលាការជឿបានថាឈ្មោះ [redacted] សេងហ៊ួយ មិនបានប្រព្រឹត្តអំពើផិតនោះទេ ។

-តាមចម្លើយរបស់ឈ្មោះ [redacted] កុសិតា បានឆ្លើយដូចគ្នានៅគ្រប់ដំណាក់ស៊ើបសួរហើយបានអះអាងថា ខ្លួននិងបងស្រីខ្លួនត្រូវឈ្មោះ [redacted] អង្គារ៉ា ស្ទាបអង្អែលប្រដាប់ភេទនៅសណ្ឋាគារប្រទេសវៀតណាម ហើយនៅទីនោះឈ្មោះ [redacted] អង្គារ៉ា បានដេកអោបថើបម្តាយខ្លួនទៀតផង ដែលចម្លើយនេះផ្ទុយទៅនឹងចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] នរតី ទាំងស្រុង ដោយឈ្មោះនេះបានបដិសេធថាឈ្មោះ [redacted] អង្គារ៉ា មិនបានស្ទាបអង្អែលប្រដាប់ភេទដូចប្អូនស្រី ឆ្លើយបំភ្លឺនោះហើយខ្លួនក៏មិនបានឃើញឈ្មោះ [redacted] អង្គារ៉ា ធ្វើអ្វីលើម្តាយខ្លួនឡើយនៅពេលស្នាក់នៅក្នុងសណ្ឋាគារប្រទេសវៀតណាម វាស្របនឹងចម្លើយរបស់ឈ្មោះ [redacted] សេងហ៊ួយ ជាមួយដែរថាខ្លួនពុំបានឃើញឈ្មោះ [redacted] អង្គារ៉ា ធ្វើអ្វីកូនខ្លួន និងខ្លួននោះទេ។ ទៀតសោតនោះឈ្មោះ [redacted] នរតី មានអាយុច្រើនជាងប្អូនរបស់ខ្លួនមានន័យថា ការយល់ដឹងរបស់ឈ្មោះ [redacted] នរតី ខ្ពស់ជាងប្អូនហើយការចងចាំក៏ប្រសើរជាងប្អូនខ្លួនដែរ ដូច្នេះការបញ្ជាក់អះអាងរបស់ឈ្មោះ [redacted] នរតី គួរអោយតុលាការជឿទុកចិត្តបាន តាមចម្លើយឈ្មោះ [redacted] សេងហ៊ួយ ឈ្មោះ [redacted] អង្គារ៉ា និងឈ្មោះ [redacted] សេងហុក ពុំបានទុកឈ្មោះ [redacted] កុសិតា នៅតែម្នាក់ឯងទេ ។

-តាមចម្លើយរបស់ឈ្មោះ [redacted] សេងហ៊ួយ ឈ្មោះ [redacted] អង្គារ៉ា និងសាក្សីឈ្មោះ [redacted] សេងហុក និងឈ្មោះ [redacted] នរតី បានបញ្ជាក់ថាក្រោយពីភ្ញាក់ពីគេងគឺពួកខ្លួនទាំងអស់គ្នាបានទៅមន្ទីរពេទ្យដោយពុំបានទុកឈ្មោះ [redacted] កុសិតា អោយនៅសណ្ឋាគារតែ២នាក់ឈ្មោះ [redacted] អង្គារ៉ា នោះទេ ។

-តាមចម្លើយឈ្មោះ [redacted] អង្គារ៉ា ឈ្មោះ [redacted] សេងហ៊ួយ និងសាក្សីឈ្មោះ [redacted] សេងហុក ឈ្មោះ [redacted] វណ្ណៈ បានឆ្លើយស៊ីសង្វាក់គ្នាថា ក្នុងពេលទៅលេងនៅខេត្តមណ្ឌលគិរីគឺពេលក្រោកពីគេងគឺនាំគ្នាស្លៀកសំលៀកបំពាក់រួចហើយក៏នាំគ្នាទៅលេងទឹកជ្រោះតែម្តងដោយពុំមានការផ្លាស់សំលៀកបំពាក់ទេ នៅកន្លែងកំសាន្តលេងទឹក ហើយក៏បានឆ្លើយស្របគ្នាដែរថា គឺឈ្មោះ [redacted] កុសិតា ពុំបានចុះទៅលេងទឹកជាមួយឈ្មោះ [redacted] អង្គារ៉ា ទេ ។

-កន្លែងកំសាន្តគឺជាទីសាធារណៈដែលមានមនុស្សច្រើនហើយការអះអាងរបស់ជនរងគ្រោះឈ្មោះ [redacted] កុសិតា ថា ឈ្មោះ [redacted] អង្គារ៉ា បានលូកប្រដាប់ភេទខ្លួនហើយពេលម្តាយខ្លួនទាន់ឈ្មោះ [redacted] អង្គារ៉ា ធ្វើជាជះទឹកដោក់នោះគឺគ្មានអ្វីអះអាងក្រៅពីលើចម្លើយជនរងគ្រោះតែប៉ុណ្ណោះ ។

-ផ្អែកតាមចម្លើយរបស់សាក្សីឈ្មោះ [redacted] សេងហុក ឈ្មោះ [redacted] វណ្ណៈ និងឈ្មោះ [redacted] នរតី ពិតជាគ្មានភស្តុតាងគ្រប់គ្រាន់ដែលបញ្ជាក់ថា ឈ្មោះ [redacted] សេងហ៊ួយ បានប្រព្រឹតអំពើ ផិត កាលពីក្នុងឆ្នាំ២០១០ តាមបញ្ញាតិមាត្រា ៧ នៃច្បាប់ស្តីពីឯកពន្ធភាព ។

-តាមដីកាសន្និដ្ឋានស្ថាពរលេខ ១៣៧២ អ,យ,ច ចុះថ្ងៃទី ២៦-០៧-២០១១ បានសំរេចលើកលែងចោទប្រកាន់ឈ្មោះ [redacted] សេងហ៊ួយ ភេទស្រី អាយុ៤១ឆ្នាំ និងឈ្មោះ [redacted] អង្គារ៉ា ភេទប្រុស អាយុ៤១ឆ្នាំ ។

-គ្មានភស្តុតាង និងពិរុទ្ធភាពដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ [redacted] **សេងហ៊ួយ** ភេទស្រី អាយុ៤១ឆ្នាំ ជាតិខ្មែរ ពីបទ **ជិត** និងឈ្មោះ [redacted] **អង្គារ៉ា** ភេទប្រុស អាយុ៤១ឆ្នាំ ជាតិខ្មែរ សញ្ជាតិបារាំង និងឈ្មោះ [redacted] **សេងហ៊ួយ** ពីបទ **អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម ១៥ឆ្នាំ** ប្រព្រឹត្តនៅប្រទេសវៀតណាម និងខេត្តមណ្ឌលគិរី កាលឆ្នាំ ២០១០ តាមបញ្ញត្តិមាត្រា ៤៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញ ដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

**<u>ហេតុដូច្នេះសំរេច</u>**

-លើកលែងចោទប្រកាន់លើ:

-ឈ្មោះ [redacted] **សេងហ៊ួយ** ភេទស្រី អាយុ៤១ឆ្នាំ ជាតិ ខ្មែរ ពីបទ **ជិត** និង **អំពើអាសប្រឆាំងនឹងអនីតិជនអាយុ ក្រោម១៥ឆ្នាំ** ប្រព្រឹត្តនៅប្រទេសវៀតណាម និងខេត្តមណ្ឌលគិរី កាលពីឆ្នាំ ២០១០ តាមបញ្ញត្តិ មាត្រា ៧ នៃច្បាប់ស្តីពីឯកពន្ធភាព និងមាត្រា ៤៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងមាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-ឈ្មោះ [redacted] **អង្គារ៉ា** ភេទប្រុស អាយុ៤១ឆ្នាំ ជាតិខ្មែរ សញ្ជាតិបារាំង ពីបទ **អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ** ប្រព្រឹត្តនៅប្រទេសវៀតណាម និងខេត្តមណ្ឌលគិរី កាលពីឆ្នាំ ២០១០ តាមបញ្ញត្តិមាត្រា ៤៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ និងមាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែសីហា ឆ្នាំ២០១១

**ចៅក្រមស៊ើបសួរ**

**ក្រឡាបញ្ជី**

[redacted] [redacted]

បានទទួលដំណឹង

លេខ

រាជធានីភ្នំពេញ ថ្ងៃទី ខែសីហា ឆ្នាំ២០១១

**តំណាងអយ្យការ**

[redacted]



Scanned with CamScanner